# សេចក្តីប្រកាសព័ត៌មាន

## *ផែនការសកម្មភាពជាតិ ត្រូវបានប្រកាសដាក់ឲ្យអនុវត្ត ដើម្បីលើកកម្ពស់ការអប់រំពហុភាសានៅកម្ពុជា ពង្រីកលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពដល់កុមារមកពីសហគមន៍ជនជាតិដើមភាគតិច*

ខេត្តក្រចេះ ប្រទេសកម្ពុជា ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦៖ ផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា ត្រូវបានប្រកាសផ្សព្វផ្សាយដាក់ឲ្យអនុវត្តនៅថ្ងៃនេះក្នុងខេត្តក្រចេះនៅក្នុងពិធីមួយក្រោមអធិបតីភាពឯកឧត្តម *បណ្ឌិត ហង់ ជួនណារ៉ុន* រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយនឹងអ្នកពាក់ព័ន្ធនិងដៃគូនានា ដូចជាតំណាងរដ្ឋាភិបាលនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សមាជិកសហគមន៍ យូនីសេហ្វ អង្គការឃែរ និងដៃគូអភិវឌ្ឍន៍ដទៃទៀត។

ផែនការសកម្មភាពជាតិនេះផ្តល់នូវផែនទីបង្ហាញផ្លូវមួយ ដើម្បីពង្រីកការអប់រំពហុភាសាដល់កុមារមកពីសហគមន៍ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជាឲ្យបានកាន់តែច្រើនថែមទៀត តាមរយៈការផ្តល់ឱកាសឲ្យពួកគេអាចរៀនសូត្រដោយប្រើភាសាកំណើតរបស់ខ្លួន ដើម្បីពង្រឹងគុណភាពនៃការរៀនសូត្ររបស់ពួកគេ។ ផែនការនេះ រួមបញ្ចូលនូវការរៀបចំផែនការសម្រាប់បង្កើនចំនួនសាលារៀនបន្ថែម ការបណ្តុះបណ្តាលគ្រូនិងការរៀបចំឯកសារបង្រៀន សម្រាប់កម្មវិធីអប់រំពហុភាសា នៅខេត្តប៉ែកឦសាននៃប្រទេសកម្ពុជាដូចជា ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ និងព្រះវិហារ។

ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា "កម្មវិធីអប់រំពហុភាសាមានសារៈសំខាន់ ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់ការអប់រំប្រកបដោយបរិយាប័ន្នភាព សមធម៌ និងគុណភាព នៅកម្ពុជា។" ឯកឧត្តមបានបន្តទៀតថា "កម្មវិធីនេះក៏ជាស្ពានសម្រាប់ភ្ជាប់កុមារកម្ពុជាដែលមិននិយាយភាសាខ្មែរនៅផ្ទះ និងផ្តល់លទ្ធភាពឲ្យកុមារជនជាតិដើមភាគតិចឲ្យបានរៀនសូត្រតាមសាលារៀនប្រកបដោយប្រសិទ្ធភាព និងយល់ពីអ្វីដែលគ្រូរបស់គេនិយាយ ក្នុងថ្នាក់រៀន។"

ផែនការសកម្មភាពជាតិនេះអនុវត្តរហូតដល់ចុងឆ្នាំ២០១៨ និងមានគោលបំណងបង្កើនចំនួនសាលាមត្តេយ្យអប់រំ ពហុភាសាឲ្យបាន ៨៨ភាគរយ (ឬ ៦៤ សាលាមត្តេយ្យ) និងសាលាបឋមសិក្សាពហុភាសាឲ្យបាន ១០០ ភាគរយ (ឬ ១០៨ សាលាបឋមសិក្សា)។

លោកស្រី ដេបូរ៉ា កូមីនី ប្រធានអង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជាមានប្រសាសន៍ថា "ផែនការនេះបង្ហាញពីឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធានាឲ្យកុមារអាចរៀនសូត្របានប្រកបដោយសមធម៌ ដោយផ្តល់ឲ្យពួកគេនូវការអប់រំ ដែលត្រូវបានរៀបចំស្របទៅតាមតម្រូវការរបស់កុមារជនជាតិដើមភាគតិច។ ជំហានសំខាន់បន្ទាប់គឺត្រូវធានាយ៉ាងណាថារាជរដ្ឋាភិបាលធ្វើការវិភាជន៍ថវិកាឲ្យបានគ្រប់គ្រាន់ ដើម្បីពង្រីកកម្មវិធីអប់រំពហុ

ភាសានេះប្រកបដោយចីរភាព។ ស្របពេលដែលការគ្របដណ្តប់នៃកម្មវិធីនេះមិនទាន់សមស្របទៅតាមទំហំនៃតម្រូវការនៃការអប់រំពហុភាសាដោយសារធនធានមានកំណត់ ការដាក់ចេញនូវផែនការជាតិនេះ គឺជាការបោះជំហានទៅមុខដ៏សំខាន់មួយ ដើម្បីឈានទៅពង្រីកការអប់រំប្រភេទនេះបន្ថែមទៀត។"

ជាមួយនឹងការគាំទ្រពីយូនីសេហ្វ និងអង្គការឃែរ បច្ចុប្បន្ននេះកម្មវិធីអប់រំពហុភាសាត្រូវបានអនុវត្តក្នុងខេត្តចំនួន៥សម្រាប់សិស្សមត្តេយ្យសិក្សា និងក្នុងខេត្តចំនួន៤ សម្រាប់សិស្សនៅបឋមសិក្សា។ រហូតមកដល់ពេលបច្ចុប្បន្ននេះ មានកុមារជាង ៥៥០០នាក់ កំពុងរៀនសូត្រនៅតាមសាលាមត្តេយ្យ និងសាលាបឋមសិក្សា ដែលអនុវត្តកម្មវិធីអប់រំពហុភាសាដោយប្រើប្រាស់ភាសាជនជាតិដើមភាគតិចចំនួន៥គឺ ព្រៅ ទំពួន គ្រឹង កាវ៉ែត និងព្នង។ កន្លងមក មានគ្រូបង្រៀនចំនួន ១៥០នាក់ បានទទួលការបណ្តុះបណ្តាលពេញលេញអំពីការអប់រំពហុភាសា។

លោកស្រី ចូអាន ហ្វៃលី ប្រធានអង្គការឃែរប្រចាំប្រទេសកម្ពុជា បានអបអរសាទរក្រសួងអប់រំ យុវជន និងកីឡាដោយសារប្រទេសកម្ពុជាជាប្រទេសទីមួយក្នុងតំបន់ ដែលបានប្រកាសផ្សព្វផ្សាយដាក់ឲ្យអនុវត្តផែនការសកម្មភាពស្តីពីការអប់រំពហុភាសាបែបនេះ។ លោកស្រីបានមានប្រសាសន៍ថា "ការប្រកាសដាក់ឲ្យអនុវត្តផែនការសកម្មភាពជាតិ នេះ គឺជាឧទាហរណ៍ដ៏វិសេសវិសាលមួយ បង្ហាញពីអត្ថប្រយោជន៍នៃភាពជាដៃគូរយៈពេលវែង។ កិច្ចសហការជាច្រើនឆ្នាំរវាងអ្នកពាក់ព័ន្ធទាំងអស់ ក្រោមកិច្ចដឹកនាំរបស់ក្រសួង និងការគាំទ្រពីអង្គការឃែរនិងយូនីសេហ្វ បាននាំឲ្យមានការរៀបចំផែនការច្បាស់លាស់មួយ ដែលនឹងផ្តល់នូវអត្ថប្រយោជន៍ទូលំទូលាយដល់កុមារមកពីសហគមន៍ជនជាតិដើមភាគតិច។ ខណៈពេលដែលការអប់រំពហុភាសាកំពុងឈានទៅដល់ដំណាក់កាលបន្ទាប់ យើងសង្ឃឹមថានឹងបន្តភាពជាដៃគូប្រកបដោយផ្លែផ្កានេះ ក៏ដូចជាស្វែងរកនូវ ឳកាសនាពេលអនាគត ដើម្បីបង្កើនលទ្ធផលនៃការអប់រំពហុភាសានេះបន្ថែមទៀត។"

មានការប៉ាន់ប្រមាណថា ប្រជាជន ៦៤ភាគរយក្នុងខេត្តរតនគិរី និង ៥៨ភាគរយក្នុងខេត្តមណ្ឌលគិរី ជាជនជាតិដើមភាគតិច។ បើតាមជំរឿនឆ្នាំ២០០៨ មានកុមារដែលមានភាសាកំណើតមិនមែនជាភាសាខ្មែរ ចំនួន ៤១ភាគរយ មិនដែលបានចូលរៀនសោះក្នុងឆ្នាំនោះ។

ការសិក្សានានាបានបង្ហាញថា កុមារងាយស្រួលរៀនភាសាទីពីរជាង ប្រសិនបើពួកគេចាប់ផ្តើមរៀនសូត្រដោយប្រើប្រាស់ភាសាកំណើតរបស់ពួកគេ។ កុមារដែលរៀននៅសាលាដោយប្រើភាសា ដែលមិនមែនជាភាសាប្រើប្រាស់នៅផ្ទះខ្លួន ច្រើនរៀនមិនពូកែ និងមិនសូវទទួលបានឳកាសពីការអប់រំ។ ការពង្រីកការអប់រំពហុភាសានេះ នឹងផ្តល់លទ្ធភាពឲ្យកុមារកាន់តែច្រើនមកពីតាមសហគមន៍ជនជាតិដើមភាគតិចនានា អាចចាប់ផ្តើមការអប់រំកម្រិតមត្តេយ្យ និងបឋមសិក្សារបស់ខ្លួន ដោយប្រើប្រាស់ភាសាកំណើតរបស់ពួកគេ ហើយជាបណ្តើរៗពួកគេចាប់ផ្តើមរៀនភាសាខ្មែរ ដែលជាភាសារបស់ជាតិ

រហូតដល់ពួកគេមានទំនុកចិត្តអាចរៀនសូត្រដោយប្រើភាសាខ្មែរពេញលេញ នៅពេលពួកគេឡើងទៅរៀននៅថ្នាក់ខ្ពស់ៗបន្តទៀត។

ផែនការសកម្មភាពជាតិនេះក៏បានដាក់ចេញនូវយុទ្ធសាស្ត្រជាច្រើន ដើម្បីធានាគុណភាព និងនិរន្តរភាពនៃកម្មវិធីអប់រំពហុភាសាដូចជា៖

- ផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់គរុសិស្សជាជនជាតិដើមភាគតិច អំពីរបៀបបង្រៀនដោយប្រើប្រាស់ពីរភាសា
- ផ្តល់ការទទួលស្គាល់ដល់គ្រូសហគមន៍ដែលបង្រៀនថ្នាក់អប់រំពហុភាសា ហើយមានសមត្ថភាពអាចបំពេញទៅតាមស្តង់ដាអប្បបរមា ដើម្បីឲ្យពួកគេអាចទទួលបានងារជាគ្រូរដ្ឋ។
- បោះពុម្ពឯកសារបង្រៀននិងរៀន ជាភាសាជនជាតិដើមភាគតិច និងធានាយ៉ាងណាឲ្យសិស្សទាំងអស់មានលទ្ធភាពទទួលបានឯកសារទាំងនោះគ្រប់គ្រាន់ និង
- ប្រែក្លាយសាលារៀនដែលផ្តល់ការអប់រំពហុភាសាតាមសហគមន៍ ឲ្យក្លាយជាសាលារៀនសាធារណៈ គ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា។

ឯកឧត្តម បណ្ឌិត ហង់ ជួនណារ៉ុន បានប្រសាសន៍បន្ថែមទៀតថា "ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តភាពជាដៃគូជាយុទ្ធសាស្ត្ររបស់ខ្លួន ជាមួយយូនីសេហ្វ និងអង្គការឃែរ ដើម្បីពង្រឹងការអប់រំពហុភាសាដល់កុមារមកពីតាមសហគមន៍ជនជាតិដើមភាគតិចនានានៅក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ ២០១៦ រដ្ឋាភិបាលមានគោលបំណងធ្វើការផ្លាស់ប្តូរងាររបស់គ្រូសហគមន៍ទាំងអស់ដែលបង្រៀនក្នុងកម្មវិធីអប់រំពហុភាសា ឲ្យក្លាយជាបុគ្គលិកដែលទទួលបានបៀវត្សរ៍ពីរដ្ឋាភិបាល ដើម្បីធានាភាពគង់វង្សនិងនិរន្តរភាពនៃការងារនេះ" ។

#####

សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីនេះ សូមមើលឯកសារព័ត៌មានអំពីកម្មវិធីការអប់រំពហុភាសាដែលបានភ្ជាប់ជូន។

## សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖


- លោក ចាន់ សុភា ប្រធាននាយកដ្ឋានបឋម ក្រសួងអប់រំ យុវជន និងកីឡា
  អ៊ីម៉ែល៖ ped@moeys.gov.kh ទូរស័ព្ទ៖ (+៨៥៥) ១២ ២១១ ៣៣៦

- លោក ជេន ន័រឡេនឌ័រ ប្រធានកម្មវិធី អង្គការឃែរ
  អ៊ីម៉ែល៖ jan.noorlander@careint.org ទូរស័ព្ទ៖ (+៨៥៥) ៨៩ ៤៩៦ ៩៦៩

- លោកស្រី អ៊ីម៉ាន ម៉ូរូកា ប្រធានផ្នែកទំនាក់ទំនង អង្គការយូនីសេហ្វប្រទេសកម្ពុជា
  អ៊ីម៉ែល៖ imorooka@unicef.org ទូរស័ព្ទ៖ (+៨៥៥) ៩២ ៥៥៥ ២៩៤

- លោក មាស ប៊ុនលី មន្ត្រីជំនាញផ្នែកទំនាក់ទំនង អង្គការយូនីសេហ្វប្រទេសកម្ពុជា
  អ៊ីម៉ែល៖ bmeas@unicef.org ទូរស័ព្ទ៖ (+៨៥៥) ១២ ៧៣៣ ៩០៩